# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៥០ សសរ

# សេចក្តីសម្រេច

## ស្តីអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ១ :** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ច ជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ដែលទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តនីច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ។

**ប្រការ២ :** ចំពោះនាយករដ្ឋមន្ត្រី : **សម្តេច ហ៊ុន សែន** : នាយករដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំរួមការងាររបស់គណៈរដ្ឋមន្ត្រី ចាត់ចែងបញ្ហារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ និងទទួលផ្ទាល់លើការងារគ្រប់គ្រងគ្រោះមហន្តរាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ៣ :** ចំពោះឧបនាយករដ្ឋមន្ត្រី :

១- ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃ ជានាយករដ្ឋមន្ត្រីស្តីទី ពេលអវត្តមាននាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី លើកិច្ចការសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជួញដូរមនុស្ស ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភេរវកម្ម ដឹកនាំកិច្ចការវិមជ្ឈការ និងសហវិមជ្ឈការ គាំទ្រកម្មវិធីសីលា ការកែទម្រង់ ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ ។ ជាមួយនេះជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងផែនការ ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។

២- ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលកិច្ចការ សំរាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារតាមដានសម្របសម្រួល និងដឹកនាំកិច្ចការកែទម្រង់រដ្ឋ ដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ការងារបំផ្លាញមីន និងជួយជនពិការដោយសារមីន និងព័ត៌មានវិទ្យា ។ ជួយនាយករដ្ឋមន្ត្រី ក្នុងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា តាមនីតិវិធីដូចមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ ។ ជាមួយនេះជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដឹកនាំអាជ្ញាធរជាតិប្រេងកាតកម្ពុជា និង អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៣- ឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងអភិវឌ្ឍន៍ជនបទ ។

៤- ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី លើការងារការពារជាតិ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការងារគ្រប់គ្រង និងបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។ ជាមួយនេះជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

៥- ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី លើការងារការបរទេស និងសហប្រតិបត្តិការអន្តរជាតិទូទៅ ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងពាណិជ្ជកម្ម និងគណៈកម្មាធិការជាតិទន្លេមេគង្គ ។

៦- ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម និងជួយឯកឧត្តម ទៀ បាញ់ ក្នុងការងារគ្រប់គ្រង និងបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។ ទន្ទឹមនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ញឹក ប៊ុនឆៃ** ជួយនាយករដ្ឋមន្ត្រី លើការងារសម្របសម្រួលគ្រប់គ្រងក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ញឹក ប៊ុនឆៃ** ដឹកនាំគណៈកម្មាធិការជាតិ ដើម្បីប្រជាជន និងការអភិវឌ្ឍន៍ គណៈកម្មការត្រួតពិនិត្យដោះស្រាយបាតុភាព និងអភិវឌ្ឍន៍ នៅតាមបណ្តោយព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង ចំណុះឱ្យអាជ្ញាធរជាតិទទួលបន្ទុក កិច្ចការព្រំដែន និងកិច្ចការមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី ។

៧- ឯកឧត្តម **កែវ ពុទ្ធរស្មី** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួល និងគ្រប់គ្រងក្រសួងកិច្ចការនារី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្រសួងធម្មការ និង កិច្ចការសាសនា និង កិច្ចការមួយចំនួនទៀត តាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី ។

**ប្រការ៤ :** នាយករដ្ឋមន្ត្រី និង ឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារតាមការកោះអញ្ជើញពីនាយករដ្ឋមន្ត្រី ឬពីនាយករដ្ឋមន្ត្រីស្តីទី ។

**ប្រការ៥ :** ឧបនាយករដ្ឋមន្ត្រីទទួលអនុវត្តការងារ ឬបេសកកម្មផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ស្របតាមមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

**ប្រការ៦ :** ឧបនាយករដ្ឋមន្ត្រី ០១ រូប១មានទីប្រឹក្សា ០៤ រូប ក្នុងនោះ ០២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ ០២ រូប មានឋានៈស្មើ អនុរដ្ឋលេខាធិការ និងជំនួយការ ០៣ រូប ក្នុងនោះ ០១ រូប មានឋានៈស្មើ អគ្គនាយក ០១ រូប មានឋានៈស្មើ អគ្គនាយករង និង ០១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ៧ :** ចំពោះទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស :

១- ព្រះអង្គម្ចាស់ក្សត្រីយ៍ **នរោត្តម ម៉ារី រណឫទ្ធិ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរអេដស៍

២- ឯកឧត្តម **ឃឹម តាំងលឹម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជារដ្ឋមន្ត្រីអមមហាអនុតំបន់ទន្លេមេគង្គ

៣- ឯកឧត្តម **វេង សិរីវុឌ្ឍ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងជាប្រធានក្រុមការងារទេសចរណ៍ សំរាប់កាត់បន្ថយភាពក្រីក្រ

៤- ឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

៥- ឯកឧត្តម **តាវ សេងហួរ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

៦- ឯកឧត្តម **លី ធុច** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ២ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**ប្រការ៨ :** ទេសរដ្ឋមន្ត្រី ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រី ប្រគល់ជូន ។

**ប្រការ៩ :** ទេសរដ្ឋមន្ត្រី ដែលទទួលបន្ទុកបេសកកម្មពិសេសមានជំនួយការ ០២ រូប ក្នុងនោះ ០១ រូប មានឋានៈស្មើអគ្គនាយករង និង ០១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ១០:** នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២-៣-៧-១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ